# សេចក្តីថ្លែងការណ៍រួម ស្តីពី
# វេទិកាកសិករថ្នាក់ជាតិ លើកទី៨
## ប្រធានបទ៖ លើកកម្ពស់ការចូលរួមដៃគូពហុភាគី
## ដើម្បីឱ្យកសិករមានលទ្ធភាពគ្រប់គ្រាន់ក្នុងការវិនិយោគលើវិស័យកសិកម្ម

រាជធានីភ្នំពេញ ថ្ងៃទី ១៦ – ១៧ ខែ តុលា ឆ្នាំ ២០១៩

យើងទាំងអស់គ្នា តំណាង កសិករ សហគមន៍កសិកម្មមកពីខេត្ត បាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង តាកែវ កំពង់ស្ពឺ ក្រចេះ កំពង់ចាម ត្បូងឃ្មុំ ស្ទឹងត្រែង រតនគិរី កំពង់ធំ សៀមរាប ព្រះវិហារ ឧត្តមានជ័យ ស្វាយរៀង ព្រៃវែង កំពត កណ្តាល និងអង្គការសង្គមស៊ីវិលរួមមាន វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGO Forum) អង្គការអាក់សិនអេតកម្ពុជា (ActionAid Cambodia) អង្គការអភិវឌ្ឍន៍ សំលេងសហគមន៍ (BCV) សមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម (CFAP-Cambodia) អង្គការភាពជាដៃគូកម្ពុជាដើម្បីកសិកម្មប្រកបដោយចីរភាព (Cambodia Partnership for sustainable Agriculture) អង្គការការីតាសកម្ពុជា (Caritas Cambodia) អង្គការការីតាសស្វីស (Swisszerland) អង្គការ CAVAC មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CEDAC) អង្គការជំនួយរបស់វិហារដាណឺម៉ាក (DCA/CA) អង្គការ Development and Peace-CARITAS CANADA អង្គការអភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព (DPA) អង្គការដាយកូនៀរ (Diakonia) អង្គការអភិវឌ្ឍន៍ និងការពារបរិស្ថាន (EPDO) សមាគមសម្របសម្រួលសេដ្ឋកិច្ចសហគមន៍កសិកម្ម (FAEC) សហព័ន្ធអង្គការកសិករកម្ពុជាដើម្បីអភិវឌ្ឍន៍ (FCFD) សមាគមបណ្តាញកសិករ និងធម្មជាតិ (FNN) សមាគមបណ្តាញកសិករនិងទឹក (FWN) កម្មវិធីជំនួយខ្នាតតូចនៃមូលនិធិបរិស្ថានពិភពលោក របស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិនៅកម្ពុជា (The GEF Small Grants Programme-UNDP Cambodia) អង្គការហេហ្វឺអន្តរជាតិ កម្ពុជា - (Heifer International Cambodia) អង្គការហេក្ស (HEKS/EPER) គម្រោង ធនធានរួមដំណោះស្រាយរួម/SRJS អង្គការសកម្មភាពដើម្បីសុខុមាលភាពស្ត្រីកម្ពុជា (KWWA) អង្គការជីវិតថ្លៃថ្នូរ (LWD) អង្គការអុកស្វាម កម្ពុជា (OXFAM in Cambodia) អង្គការព្រហ្មវិហារធម៌ (PVT) សមាគមក្រុមអភិវឌ្ឍន៍ភូមិ (KAWP) អង្គការសង្គ្រោះសត្វព្រៃ (SCW) គម្រោងឈេន នៃអង្គការ SNV អង្គការស្តារកម្ពុជា (SK) ក្រុមទ្រទ្រង់ភូមិ (VSG) និងអង្គការសង្គមស៊ីវិលផ្សេងៗ សូមធ្វើសេចក្តីថ្លែងការណ៍រួមនៃ **វេទិកាកសិករថ្នាក់ជាតិ លើកទី៨៖ ក្រោមប្រធានបទ៖ "លើកកម្ពស់ការចូលរួមដៃគូពហុភាគីដើម្បីឱ្យកសិករមានលទ្ធភាពគ្រប់គ្រាន់ក្នុងការវិនិយោគលើវិស័យកសិកម្ម"** ថ្ងៃទី

១៦-១៧ ខែតុលា ឆ្នាំ២០១៩ នៅភោជនីយដ្ឋានទន្លេបាសាក់២រាជធានីភ្នំពេញ។ គោលបំណងនៃសេចក្តីថ្លែងការណ៍នេះដើម្បីទាញយកការយកចិត្តទុកដាក់បន្ថែមទៀតពីស្ថាប័នពាក់ព័ន្ធនានាដើម្បីជួយដោះស្រាយ និងគាំទ្រដល់កសិកកម្មជាអោយកាន់តែមានជីវភាព និងភាពធន់កាន់តែល្អប្រសើរឡើងថែម ទៀត។ វេទិកាដ៏មានសារៈសំខាន់នេះបានពិភាក្សាទៅលើប្រធានបទចម្បងៗចំនួន ៣ ដែលរួមមាន៖

- ការចូលរួមរបស់ពហុភាគីក្នុងកសិធុរៈកិច្ចដើម្បីជួយកសិករមានលទ្ធភាពទទួលបានទឹកសម្រាប់កសិកម្ម
- ការចូលរួមរបស់ពហុភាគីក្នុងកសិធុរៈកិច្ចដើម្បីជួយកសិករមានលទ្ធភាពទទួលបានទុនសម្រាប់កសិកម្ម
- ការចូលរួមរបស់ពហុភាគីក្នុងកសិធុរៈកិច្ចដើម្បីជួយកសិករមានលទ្ធភាពចូលទីផ្សារកសិកម្ម

## លទ្ធផលសំខាន់ៗដែលទទួលបានពីវេទិកាពិភាក្សាទាំង ៣ មានដូចតទៅ៖

ការវិនិយោគលើ និងការទទួលបាន **ទឹក ទុន** និង**ទីផ្សារ** គឺចាំបាច់ណាស់សម្រាប់កសិករដើម្បីទទួលជោគជ័យក្នុងការវិនិយោគលើវិស័យកសិកម្មជាពិសេសកសិករខ្នាតតូច។ ទោះជាយ៉ាងណាក៏ដោយ ការប្រែប្រួលអាកាសធាតុ សមត្ថភាពរបស់កសិករក្នុងការទទួលបានទុនមកវិនិយោគ និងការទទួលបានព័ត៌មានទីផ្សារកសិកម្ម នៅតែជាបញ្ហាប្រឈមមានដូចខាងក្រោម៖

- សហគមន៍ប្រើប្រាស់ទឹកត្រូវមាន ***ផែនការគ្រប់គ្រង និងបែងចែកទឹកឱ្យបានត្រឹមត្រូវ និងសមធម៌***។ សហគមន៍កសិកម្មនៅតែជួប **បញ្ហាប្រឈមអំពីការប្រមូលថវិកាសម្រាប់ការគ្រប់គ្រង និងការថែទាំទៅលើប្រព័ន្ធធារាសាស្ត្រនានា** និងការ **មិនសូវមានការចូលរួម និងយកចិត្តទុកដាក់ឱ្យបានខ្លាំងពីអាជ្ញាធរមូលដ្ឋាន** ក្នុងការដោះស្រាយបញ្ហានៃការប្រើប្រាស់ទឹក និងការប្រមូលថវិកាបដិភាគ។ ម្យ៉ាងទៀត **ការគាំទ្រ និងការទទួលស្គាល់ជាផ្លូវការទៅលើសហគមន៍កសិកម្ម** នៅតែជាបញ្ហាប្រឈម។
- **សហគមន៍កសិកម្មខ្លួនឯងត្រូវមានភាពដឹកនាំខ្លាំងនៅក្នុងសហគមន៍** រួមទាំងសមត្ថភាពក្នុងការគ្រប់គ្រងលើហិរញ្ញវត្ថុ និងការចាត់ចែងចំណាយនានា។ ម្យ៉ាងទៀតសហគមន៍ត្រូវមានផែនការជំនួញឱ្យបានច្បាស់លាស់ដែលជួយដល់ការវិនិយោគរបស់ខ្លួន និងការទាក់ទាញសម្រាប់កម្ចីពីធនាគារ។
- រាជរដ្ឋាភិបាល និងសហគមន៍កសិកម្មត្រូវមាន **យុទ្ធសាស្ត្រច្បាស់លាស់ និងយូរអង្វែងក្នុងការប្រើប្រាស់ទឹកជាពិសេសទឹកក្រោមដី** ចំពោះដំណាំមួយចំនួនដូចជាម្រេចជាដើម។
- រាជរដ្ឋាភិបាល និងសហគមន៍កសិកម្មត្រូវធានាឱ្យមានធនធានទឹកស្អាតសម្រាប់បរិភោគ និងការប្រើប្រាស់នៅក្នុងផ្ទះផងដែរ។
- ទាំងរាជរដ្ឋាភិបាល និងសហគមន៍កសិកម្មត្រូវតែមាន **ការសិក្សាស្វែងយល់ឱ្យបានច្បាស់លាស់អំពីបរិមាណទឹកតម្រូវការ និងការចាត់ចែងធនធានទឹកឱ្យមានតម្លាភាព** និងមានការចូលរួមឱ្យបានគ្រប់គ្រាន់ពីភាគីពាក់ព័ន្ធ។

- ធនាគារផ្តល់កម្ចីត្រូវ **ជួយសម្រួលឯកសារកម្ចីកុំឱ្យមានភាពស្មុគស្មាញពេកសម្រាប់សហគមន៍កសិកម្ម** និងសមាជិកសហគមន៍ និងជួយផ្តល់ការប្រឹក្សាយោបល់ឱ្យចំគោលដៅមុនពេលអនុម័តកម្ចី។ ជាងនេះទៅទៀត ធនាគារ **គួរពិចារណាផ្តល់កម្ចីដល់សហគមន៍ឱ្យបានច្រើន** និងឱ្យមានភាពងាយស្រួល។ម្យ៉ាងវិញទៀតអត្រាការប្រាក់ពីធនាគារឯកជនត្រូវ **ជួយសម្រួលឱ្យមានអត្រាទាប** ត្រឹម៨%ក្នុង១ឆ្នាំ។
- ផ្សារមានការរីកចម្រើនបានទាល់តែមានទំនិញច្រើន សម្បូរណ៍បែប និងមានគុណភាព។ ការស្វែងរកទីផ្សារសម្រាប់ផលិតផលកសិកម្មជាបញ្ហាសំខាន់ ប៉ុន្តែ **ការរក្សា និងស្ថេរភាពទីផ្សារជាយុទ្ធសាស្ត្រសំខាន់ក្នុងការគ្រប់គ្រង និងទាញយកផលប្រយោជន៍ពីទីផ្សារទាំងនោះ**។
- **កសិករម្នាក់ត្រូវក្លាយជាពាណិជ្ជករម្នាក់** ដែលត្រូវរកស៊ីដោយប្រុងប្រយ័ត្ន និងមិនត្រូវចេះធ្វើតាមការនឹកឃើញទេ ហើយត្រូវចេះទាញយកផលប្រយោជន៍ពីបរិបទនៃឧស្សាហកម្ម ៤.០ ក្នុងការផ្សព្វផ្សាយនិងលក់ផលិតផលកសិកម្មរបស់កសិករ។
- សហគមន៍កសិកម្មត្រូវ **បង្កើតនូវឯកទេសសកម្មទៅលើផលិតផលកសិកម្ម** ដូចជាត្រសក់ផ្អែមតាមតំបន់ជាក់លាក់ណាមួយ។ សហគមន៍ត្រូវចងចាំថាទំនិញកសិកម្មជាទំនិញដែលងាយនឹងខាត ចំណេញ និងមានហានិភ័យខ្ពស់។
- **កសិករខ្នាតតូចត្រូវទទួលបានទីផ្សារត្រឹមត្រូវ ស្ថេរភាព និងផល ប្រយោជន៍ដោយយុត្តិធម៌**។
- ក្នុងការស្វែងរកទីផ្សារ សហគមន៍ត្រូវមានការ **សិក្សាស្រាវជ្រាវរកផលិតផលណាដែលសមាជិកដាំទៅចំណេញ** ដោយការចុះស្ទង់ទីផ្សារ និងសិក្សាតម្លៃប៉ុន្មានក្នុងរយៈពេល ៣ឆ្នាំជាដើម។ ការសិក្សាស្រាវជ្រាវជាមុនសិន ដើម្បីឱ្យការផលិតត្រូវតាមទីផ្សារ។ សហគមន៍ខ្លួនឯងត្រូវមានតំណាងសិក្សាស្រាវជ្រាវ និងសិក្សាវាយតម្លៃទីផ្សារ។ មុននឹងបង្កើតក្រុមដាំ សហគមន៍ត្រូវសិក្សាតម្រូវការទីផ្សារជាមុនសិន។ កុំដាំហើយ ទៅរកទីផ្សារ។
- សហគមន៍ត្រូវធ្វើ **ផែនការយុទ្ធសាស្ត្រក្នុងការធ្វើពហុភាពទីផ្សារ** ដែលជារឿងសំខាន់ និងជាអាទិភាពសម្រាប់រក្សាទីផ្សារ និងបន្សាំទៅទីផ្សារដែលមានតម្រូវការផ្សេងៗគ្នា។
- ការធ្វើអាជីវកម្មគោរពតាមគោលការណ៍ ១) ផ្តោតលើ **បរិស្ថានស្អាត** តាមរយៈការផលិតផលិតផលសរីរាង្គនិងសុវត្ថិភាព ២) គិតគូរទៅលើ **សុខភាពរបស់មនុស្ស** តាមរយៈកសិកម្មសរីរាង្គ ៣) ផ្តល់ **ទំនុកចិត្តខ្ពស់រវាងដៃគូ និងអ្នកពាក់ព័ន្ធ** និងការធ្វើអាជីវកម្មបែបបរិយាប័ន (ដោយគាំទ្រដល់កសិករក្រីក្រផងដែរ)។

## អនុសាសន៍បន្ថែមរួមមាន៖

- បន្តកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធពិសេសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងពាណិជ្ជកម្ម ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងបរិស្ថាន ក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីអនុវត្ត និងតាមដានលទ្ធផលដែលបានលើកឡើងក្នុងផែនការសកម្មភាពដែលសម្រេចបាននៅក្នុងការពិភាក្សានៃវេទិកាកសិករថ្នាក់ជាតិ លើកទី៨។

- អង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាពិសេស អគ្គនាយកដ្ឋានកសិកម្មត្រូវយកចិត្តទុកដាក់ក្នុងការពង្រឹងសិទ្ធិអំណាច និងផ្តល់ឱកាសដល់កសិករខ្នាតតូចក្នុងការសម្រេចចិត្ត និងបន្តជំរុញសហគមន៍កសិកម្មឱ្យកាន់ទូលំទូលាយ និងរឹងមាំដើម្បីជំរុញនូវក្រុមអ្នកផលិតខ្នាតតូច ព្រមទាំងធានានូវលំនឹងទីផ្សារផលិតផលកសិកម្ម ដើម្បីបំពេញទៅនឹងតម្រូវការទីផ្សារក្នុងស្រុក និងបង្កើតឱ្យមានខ្សែច្រវ៉ាក់ផលិតកម្ម។
- ត្រូវធ្វើការផ្សព្វផ្សាយព័ត៌មានទីផ្សារផលិតផលកសិកម្ម និងបច្ចេកទេសកសិកម្មឱ្យបានទូលំ ទូលាយទៅដល់កសិករ ជាពិសេសកសិករខ្នាតតូច។
- មន្ទីរពិសោធន៍ត្រូវយកចិត្តទុកដាក់ស្រាវជ្រាវពូជធន់នឹងការរាំងស្ងួត ធន់នឹងជម្ងឺ ធន់នឹងសត្វល្អិតចង្រៃ ពូជមានរយៈពេលខ្លីដែលបន្សាំទៅនឹងប្រែប្រួលអាកាសធាតុ និងទទួលបានទិន្នផលខ្ពស់។
- ស្ថាប័នរាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធទាំងអស់រួមទាំងអង្គការសង្គមស៊ីវិល និងវិស័យឯកជនតំណាងកសិករ បន្តការសិក្សា និងស្វែងរកយន្តការលម្អិតក្នុងការតាមដានការអនុវត្តផែនការសកម្មភាពដែលសម្រេចបាននៅក្នុងអង្គវេទិកានេះ ត្រូវជំរុញ លើកទឹកចិត្ត និងផ្តល់ឱកាស ដល់កសិករក្នុងការលើកឡើងពីបញ្ហាប្រឈមនានា សំណូមពរ និងចែករំលែកនូវបទពិសោធន៍ នានាទាក់ទងនឹងការគ្រប់គ្រង និងស្វែងរកទីផ្សារ ទុន និងទឹកក្នុងដំណើរការផលិតផលកសិកម្ម។
- អង្គការសង្គមស៊ីវិល វិស័យឯកជន និងដៃគូអភិវឌ្ឍន៍គួរតែបន្តការអនុវត្តសកម្មភាពដែលមានកន្លងមក និងស្វែងរកនូវយុទ្ធសាស្ត្រ ឬសកម្មភាពថ្មីៗ ក្នុងការជំរុញ និងពង្រឹងនូវសមត្ថភាពបន្សាំរបស់កសិករទៅនឹងការប្រែប្រួលអាកាសធាតុឱ្យកាន់តែមានភាពប្រសើរឡើង ជាពិសេសផ្តោតទៅលើកសិករខ្នាតតូច និងងាយរងគ្រោះ ព្រមទាំងលើកទឹកចិត្តក្នុងការស្វែងរកនូវ ទីផ្សារផលិតផលកសិកម្ម។
- កសិករគួរជំរុញការចងក្រងជាក្រុម និងបង្កើតសហគមន៍កសិកម្ម ដើម្បីបង្កើតជាសម្លេងមួយក្នុងការធានានូវការគ្រប់គ្រងនូវតម្លៃផលិតផលកសិកម្ម ការផ្គត់ផ្គង់ និងការចបារទីផ្សារក្នុង តំបន់សម្រាប់ផលិតផលកសិកម្ម។ កសិករត្រូវមានការផ្លាស់ប្តូរនូវទម្លាប់ចាស់ដែលធ្លាប់អនុវត្តកន្លងមកទៅលើបច្ចេកទេសកសិកម្ម ព្រមទាំងជំរុញ និងពង្រឹងការសិក្សាស្វែងយល់ពីគ្នាទៅវិញទៅមករវាងកសិករ និងកសិករ និងអ្នកពាក់ព័ន្ធនានាដើម្បីពង្រឹងសមត្ថភាពក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយនូវផលប៉ះពាល់ដែលបណ្តាលមកពីគ្រោះមហន្តរាយនៃការប្រែប្រួលអាកាសធាតុនាពេលបច្ចុប្បន្ន និងទៅអនាគត។

## ផែនការសកម្មភាពរួម

តាមរយៈកិច្ចពិភាក្សារួមរវាងដៃគូពាក់ព័ន្ធ រួមមាន៖ តំណាងរាជរដ្ឋាភិបាល វិស័យឯកជន ដៃគូអភិវឌ្ឍ អង្គការ សង្គមស៊ីវិលជាតិ និងអន្តរជាតិ ជាពិសេសសហគមន៍កសិករ បានដាក់ចេញនូវសកម្មភាពរួមដូចខាងក្រោម៖

- ការប្រមូលផ្តុំក្រុមផលិត ជាគន្លឹះសំខាន់សម្រាប់ឆ្លើយតបទៅទីផ្សារដែលត្រូវការអ្វីមួយ ដែលច្បាស់លាស់ ទាំងបរិមាណនិងគុណភាពដែលនេះជាចំណុចខ្លាំងរបស់សហគមន៍។ សហគមន៍

គួរតែមានអ្វីមួយជាស្នាដៃរបស់ខ្លួនដើម្បីទាក់ទាញទំនុកចិត្ត និងការវិនិយោគបន្ត។ ក្រុមផលិតចាំបាច់ត្រូវតែជាចងគ្នាជាចង្កោមដែលរឹងមាំ ក្នុងការផលិតប្រភេទស្រូវតែមួយ ឬផលិតផលតាមទីផ្សារ។ កសិករខ្លះផលិតតាមចិត្ត ហើយពេលប្រមូលផល និងការដឹកជញ្ជូនមានការលំបាក និងត្រូវការចំណាយច្រើន។ សហគមន៍គួរតែផលិតដោយមានផែនការ និងកិច្ចសន្យាត្រឹមត្រូវ ក្នុងការធានាបានបរិមាណ និងគុណភាពសម្រាប់ផ្គត់ផ្គង់ទីផ្សារក្នុងការកាត់ចំណាយប្រតិបត្តិការរបស់ក្រុមហ៊ុនឯកជន និងកសិករខ្លួនឯង។

- យើងត្រូវពង្រឹងភាពជាដៃគូក្នុងការសហការរវាងរាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងវិស័យឯកជន។
- ការកំណត់ឱ្យបានជាក់លាក់នូវតំបន់ភូមិសាស្ត្រទៅលើការផលិតផលិតផលណាមួយ ដូចជាបន្លែ ផ្លែឈើ។ រាជរដ្ឋាភិបាលកម្ពុជាត្រូវកំណត់ទីតាំងណាដែលអាចដាំអ្វីបានសម្រាប់ជំរុញការលើកកម្ពស់ និងអនុវត្តការផលិត ផលិតផលកសិកម្ម។
- កន្លែងប្រមូលផ្តុំស្តុកទុកផលិតផលនៅតែជាបញ្ហាក្នុងការធានាបាននូវស្តង់ដារសុវត្ថិភាពចំណីអាហារអនាម័យ និងការវេចខ្ចប់នានា។ ក្រុមហ៊ុនឯកជនអាចជួយបង្កើតទីតាំងមួយឱ្យត្រឹមត្រូវតាមស្តង់ដារជាតិដែលអាចទទួលយកបាន។ ប្រព័ន្ធគ្រប់គ្រងគុណភាពស្តង់ដារចំណីអាហារត្រូវមានការរៀបចំ និងធ្វើឱ្យប្រសើរឡើងជាចាំបាច់។ វិស័យឯកជនអាចជួយបណ្តុះបណ្តាលដល់សហគមន៍កសិកម្មក្នុងការផលិត និងកែច្នៃផលិតផលឱ្យបានត្រឹមត្រូវ។
- ការគ្រប់គ្រងក្រោយការប្រមូលផលចាំបាច់ត្រូវតែគិតគូរឡើងវិញ ដើម្បីកាត់បន្ថយការខូតខាត បាត់បង់ និងការបង្កើនគុណភាពផលិតផលកសិកម្ម ដែលបញ្ហានេះអាចជួយធានាដល់ទីផ្សារផងដែរ។ វិស័យឯកជនត្រូវគិតគូរក្នុងការជម្រុញ កសិកម្មតាមកិច្ចសន្យាឱ្យបានច្រើនជាមួយសហគមន៍ផងដែរ។
- ការផលិតរបស់សហគមន៍ត្រូវតែមានភាពចំណេញ និងផែនការលក់ដូរឱ្យបានច្បាស់លាស់។ ការចុះកិច្ចសន្យាកសិកម្មរវាងអ្នកផលិត និងអ្នកទិញជាពិសេសស្រូវ និងបន្តទៀតជាមួយបន្លែ និងការចិញ្ចឹមសត្វត្រូវតែយកមកពិចារណាសម្រាប់សហគមន៍កសិកម្ម និងក្រុមហ៊ុនឯកជន។ ការពង្រឹងសមត្ថភាពសហគមន៍ទាំងហិរញ្ញវត្ថុ និងផែនការអាជីវកម្មជាគន្លឹះ ដែលមិនអាចខ្វះបាន។ ត្រូវចាំថានៅពេលសហគមន៍រឹងមាំ នោះធនាគារនឹងមករកយើងដាក់កម្ចីវិញហើយ។
- ធនាគារបានកំពុងធ្វើទំនើបកម្មសេវាកម្មធនាគារ។ ធនាគារបានកំពុងគិតអំពីការរៀបចំឯកសារឱ្យបានងាយស្រួលតាមបរិបទឧស្សាហកម្ម ៤.០។ កសិករអាចប្រើប្រាស់កម្មវិធីទូរស័ព្ទដៃ ហើយធនាគារនឹងចុះមកជួបពិភាក្សាអំពីកម្ចីផ្ទាល់តែម្តង។ ម្យ៉ាងទៀត គ្រាន់តែបុគ្គលិកធនាគារសម្ភាសកសិករនៅតាមផ្ទះ របាយការណ៍នឹងបញ្ជូនមកកាន់ធនាគារភ្លាមៗសម្រាប់ការពិចារ ណារក្នុងការផ្តល់កម្ចី។ នៅពេលកសិករបើកលុយពីកម្ចី កសិករអាចបើកតាមក្រុមហ៊ុន និងបញ្ជរឯកជននានាដោយមិនចាំបាច់មកធនាគារ។ សូមមេត្តាផ្តល់ព័ត៌មានឱ្យបានពិត ពេលបុគ្គលិកធនាគារចុះទៅវាយតម្លៃដើម្បីធនាគារជួយពិភាក្សាអំពីការប្រាក់ និងការសងប្រាក់ និងដើម្បីឱ្យរួចផុតពីបំណុល។
- រាជរដ្ឋាភិបាលកម្ពុជា ត្រូវធានាឱ្យមានភាពស៊ីគ្នារវាងរបាយការណ៍ហិរញ្ញវត្ថុរបស់សហគមន៍កសិកម្មដែលធនាគារអាចទទួលយកបានសម្រាប់ការវាយតម្លៃក្នុងការផ្តល់កម្ចី។ សហគមន៍កសិកម្មត្រូវមានការកត់ត្រា និងឯកសារត្រឹមត្រូវអំពីលំហូរសាច់ប្រាក់ និងការចំណេញរបស់អាជីវកម្មសហគមន៍ក្នុង

ចន្លោះពេលណា ដែលធ្វើឱ្យធនាគារមានភាពងាយស្រួលវាយតម្លៃ។ម្យ៉ាងទៀត ដៃគូរសហការត្រូវជួយពង្រឹងតម្លាភាពរបស់គណៈកម្មការរបស់សហគមន៍ផងដែរដើម្បីកាត់បន្ថយការលំបាកសម្រាប់ធនាគារក្នុងការផ្តល់កម្ចី។

- អត្រាការប្រាក់ ( ដោយទុនដើមរបស់ធនាគារថ្លៃ ) ដូច្នោះអត្រាការប្រាក់ពិបាកនឹងបញ្ចុះណាស់។ បើរដ្ឋាភិបាលកម្ពុជាអាចជួយសម្រួលឱ្យបានទុនដែលមានថ្លៃទាប  នោះធនាគារអាចជួយបន្ថយការប្រាក់ដល់កសិករដែរ។
- រាជរដ្ឋាភិបាលកម្ពុជា និងអង្គការស្ថាប័ននានា ត្រូវបន្តលើកកម្ពស់  និងជំរុញគម្រោងភូមិមួយផលិតផលមួយដើម្បីរួមចំណែកដល់ការពង្រឹងគុណភាព និងទីផ្សារសម្រាប់ផលិតផលរបស់សហគមន៍កសិកម្ម។

បញ្ជីរាយនាម អង្គការសង្គមស៊ីវិល និងដៃគូរអភិវឌ្ឍន៍ គាំទ្រលើសេចក្ដីថ្លែងការណ៍៖

| No | ឈ្មោះជាភាសាខ្មែរ | ឈ្មោះជាភាសាអង់គ្លេស |
|---|---|---|
| 1 | អង្គការអេក់សិនអេតកម្ពុជា | ActionAid Cambodia |
| 2 | អង្គការអភិវឌ្ឍន៍សំលេងសហគមន៍ | Building Community Voices |
| 3 | សមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម | Cambodian Farmer Federation Association of Agricultural Producers |
| 4 | ភាពជាដៃគូកម្ពុជាដើម្បីកសិកម្មប្រកបដោយចីរភាព | Cambodia Partnership for sustainable Agriculture |
| 5 | អង្គការការីតាសកម្ពុជា | Caritas Cambodia |
| 6 | អង្គការ ការីតាស Swisszerland | CARITAS Swisszerland |
| 7 | គម្រោងCAVAC | CAVAC |
| 8 | មជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា | Cambodian Center for Study and Development in Agriculture ( CEDAC ) |
| 9 | អង្គការជំនួយរបស់វិហារដាណឺម៉ាក | DCA/CA |
| 10 | Development and Peace—CARITAS CANADA | Development and Peace—CARITAS CANADA |
| 11 | អង្គការ អភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព | Development and Partnership in Action |
| 12 | មជ្ឈមណ្ឌលដាយកូនៀរ | Diakonia Centre |
| 13 | អង្គការអភិវឌ្ឍន៍ និងការពារបរិស្ថាន | Environmental Protection and Development Organization |
| 14 | សមាគមសម្របសម្រួលសេដ្ឋកិច្ចសហគមន៍កសិកម្ម | Facilitation Association of Economy for Cooperatives |
| 15 | សហព័ន្ធអង្គការកសិករកម្ពុជាដើម្បីអភិវឌ្ឍន៍ | Federation of Cambodian Farmer Organizations for Development |
| 16 | សមាគមបណ្ដាញកសិករនិងធម្មជាតិ | Farmer Nature Net Association |
| 17 | បណ្ដាញកសិករ និងទឹក | Farmer and Water Net |
| 18 | កម្មវិធីជំនួយខ្នាតតូចនៃមូលនិធិបរិស្ថានពិភពលោករបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិនៅកម្ពុជា | The GEF Small Grants Programme—UNDP Cambodia |
| 19 | អង្គការហេហ្វឺអន្តរជាតិ កម្ពុជា - | Heifer International Cambodia |
| 20 | អង្គការហេក្ស | HEKS/EPER |
| 21 | គម្រោង គម្រោងធនធានរួមដំណោះស្រាយរួម | SRJS Project |

| | | |
|---|---|---|
| 22 | អង្គការ សកម្មភាពដើម្បីសុខុមាលភាពស្ត្រីកម្ពុជា | KAMPUCHEA WOMEN'S WELLFARE ACTION |
| 23 | អង្គការជីវិតថ្លៃថ្នូរ | Life With Dignity |
| 24 | វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា | The NGO Forum on Cambodia |
| 25 | អង្គការ អុកស្វាម កម្ពុជា | OXFAM in Cambodia |
| 26 | អង្គការព្រហ្មវិហារធម៌ | PROMVIHEARTOR ORGANIZATION |
| 27 | សមាគមក្រុមអភិវឌ្ឍន៍ភូមិ | SAMAKUM KROM AKPHIWAT PHUM |
| 28 | អង្គការសង្គ្រោះសត្វព្រៃ | Save Cambodia's Wildlife |
| 29 | អង្គការ SNV គម្រោងឈេន | SNV Netherlands Development Organisation—CHAIN Programme |
| 30 | អង្គការស្តារកម្ពុជា | STAR KAMPUCHEA |
| 31 | ក្រុមទ្រទ្រង់ភូមិ | Village Support Group |